**នៅចំពោះមុខអង្គបុរេជំនុំជម្រះ**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification):
06 / 03 / 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

| | |
|---|---|
| សំណុំរឿងលេខ: | ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស (អ.ប.ជ ០១-០៣) |
| បញ្ជូនទៅ: | អង្គបុរេជំនុំជម្រះ |
| កាលបរិច្ឆេទនៃការបញ្ជូន | ថ្ងៃទី៦ ខែមិនា ឆ្នាំ២០០៨ |
| ភាគីបញ្ជូន: | នួន ជា<br>អៀង សារី<br>អៀង ធីរិទ្ធ និង |
| ភាសាដើម: | ខ្មែរ និង អង់គ្លេស |
| ប្រភេទឯកសារ: | សាធារណៈ |

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception):
06 / 03 / 2008
ម៉ោង (Time/Heure): 15 : 30 PM
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

# សេចក្ដីសន្និដ្ឋានឆ្លើយតបរួមគ្នាចំពោះសារណាស្ដីពីការចូលរួមរបស់ដើមបណ្ដឹងរដ្ឋប្បវេណីក្នុងរឿងបណ្ដឹងឧទ្ធរណ៍ជំទាស់នឹងដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន

<u>បញ្ជូនដោយ៖</u>

**សហមេធាវីការពារលោក នួន ជា**
លោកមេធាវី សុន អរុណ
លោកមេធាវី Michiel PESTMAN
លោកមេធាវី Victor KOPPE

**សហមេធាវីការពារលោក អៀង សារី**
លោកមេធាវី អាង ឧត្តម
លោកមេធាវី Michael KARNAVAS

**មេធាវីការពារ និងទីប្រឹក្សាច្បាប់របស់**
**អ្នកស្រី អៀង ធីរិទ្ធ**
លោកមេធាវី ផាត់ ពៅស៊ាង
កញ្ញា Diana ELLIS QC

<u>អ្នកទទួលឯកសារ:</u>

**ចៅក្រមនៃអង្គបុរេជំនុំជម្រះ**
លោក ប្រាក់ គឹមសាន
លោក ន័យ ថុល
លោក ហួត វុទ្ធី
លោកស្រី Katinka LAHUIS
លោក Rowan DOWNING

**សហព្រះរាជអាជ្ញា**
លោកស្រី ជា លាង
លោក Robert PETIT

**មេធាវីរបស់ដើមបណ្ដឹងរដ្ឋប្បវេណី៖**
លោកមេធាវី ហុង គឹមសួន
លោកមេធាវី ឡោ ជុនធី និងលោកមេធាវីនីចាន់ ឌី

# I. សេចក្តីផ្តើម

1. មេធាវីការពារក្តីរបស់ជនត្រូវចោទ នួន ជា, អៀង សារី និង អៀង ធីរិទ្ធ (ហៅថា"មេធាវីការពារក្តី"រួមគ្នា) សុំដាក់សេចក្តីសន្និដ្ឋានឆ្លើយតបរួមគ្នាចំពោះសារណាជាច្រើនស្តីពីការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងរឿងបណ្តឹងឧទ្ធរណ៍ជំទាស់នឹងការសម្រេចឃុំខ្លួនបណ្តោះអាសន្ន[1]។ សារណាជាច្រើន រួមបញ្ចូលទាំងសារណារបស់ការិយាល័យសហព្រះរាជអាជ្ញា (ហៅថា "ក.ស.ព") និងភាគីដើមបណ្តឹងរដ្ឋប្បវេណី ( "ដើមបណ្តឹងរដ្ឋប្បវេណី") ផង បានលើកឡើងតែពីតួនាទីរបស់ដើមបណ្តឹងរដ្ឋប្បវេណីតែប៉ុណ្ណោះ[2] ហើយទន្ទឹមគ្នានេះដែរ មានតែសារណារបស់អ្នកដែលមិនមែនភាគីតុលាការតែម្នាក់គត់ជំទាស់ទៅនឹងការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដោយគ្មានអញ្ញត្រកម្ម[3] ។ អាស្រ័យហេតុនេះ មេធាវីការពារក្តីយល់ព្រមលើសារណាចុងក្រោយទាំងស្រុង ហើយសុំធ្វើការឆ្លើយតបចំពោះសារណាទាំងនោះដូចខាងក្រោម ។

# II. អំណះអំណាង

## ក. បញ្ហាបឋម

### ១. សារណាមួយចំនួនឋិតនៅក្រៅវិសាលភាពរបស់ដីកា

2. អនុលោមទៅតាមវិធាន ៣៣ នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក (ហៅថា"វិធានផ្ទៃក្នុង") "បើយល់ថាចាំបាច់ដើម្បីវិនិច្ឆ័យទោសឲ្យបានត្រឹមត្រូវ អង្គជំនុំជម្រះអាចអញ្ជើញ ឬ ផ្តល់ឱកាសឲ្យអង្គការ ឬ បុគ្គលណាមួយប្រគល់ជូននូវសារណាជាលាយល័ក្ខអក្សរ ពាក់ព័ន្ធទៅនឹងបញ្ហាណាមួយក៏បានក្នុងនាមជាអ្នកដែលមិនមែនជាភាគីតុលាការ" ។ នៅក្នុងដីការបស់ខ្លួនចុះនៅថ្ងៃទី ១២ ខែកុម្ភៈ ឆ្នាំ២០០៨ អង្គបុរេជំនុំជម្រះ ( "អ.ប.ជ.") អំពាវនាវឲ្យមានការចូលរួមដាក់ "សារណាពីអ្នកដែលមិនមែនជាភាគីតុលាការ ដោយផ្តោតទៅលើតែបញ្ហាតុល្យភាពរវាងសិទ្ធិរបស់ជនត្រូវចោទក្នុងការទទួលបានការកាត់សេចក្តីដោយយុត្តិធម៌ និងសិទ្ធិរបស់ដើមបណ្តឹងរដ្ឋរប្បវេណី នៅក្នុងបរិបទនៃវិធានផ្ទៃក្នុងរបស់

---

[1] សូមមើលឯកសារលេខ C-11/38/44 ។

[2] សូមមើលឯកសារលេខ C-11/38 និង C-11/44 ( "សារណាសំខាន់រួមគ្នា")

[3] សូមមើលឯកសារលេខ C-11/39 ("សារណារបស់ Safferling")

អ.វ.ត.ក” តែប៉ុណ្ណោះ[4]។ ក្នុងខណៈជាបញ្ហាទូទៅ តុលាការព្រហ្មទណ្ឌអន្តរជាតិនានាយល់ឃើញថា វាជាការចាំបាច់ដើម្បីដាក់កម្រិតការចូលអន្តរាគមន៍របស់អ្នកដែលមិនមែនជាភាគីតុលាការ ផ្អែកលើមូលហេតុនៃចំណាយរបស់តុលាការ ដោយពិចារណាលើផលប្រយោជន៍ខ្ពស់នៅក្នុងបញ្ហាដែលកើតឡើងនៅក្នុងតុលាការទាំងនេះ ។ ជាការពិតណាស់ ជំនួយដែលផ្តល់ដោយអ្នកដែលមិនមែនជាភាគីតុលាការ គឺចាំបាច់ក្នុងការវិនិច្ឆ័យលើករណីឲ្យបានត្រឹមត្រូវ[5] តែជំនួយបែបនេះត្រូវកំណត់ចំពោះបញ្ហាជាក់លាក់ដែលកំណត់ដោយតុលាការ[6] ។ ការដាក់កំហិតបែបនេះ គឺជាប់ពាក់ព័ន្ធជាពិសេសជាមួយ អ.វ.ត.ក ដោយ ពិចារណាលើវិបត្តិថវិកានាពេលបច្ចុប្បន្ននេះ និងការលំបាកក្នុងការបកប្រែឯកសារ ។

3. ពិចារណាលើខ្លឹមសាររបស់ដីកា និង គោលការណ៍នៃច្បាប់អន្តរជាតិដែលបានពោលពីខាងលើ សារណាភាគច្រើនរបស់អ្នកដែលមិនមែនភាគី គឺមិនអាចទទួលយកបានទេ ដោយសារតែសារណាទាំងនោះមិនបានគូសបញ្ជាក់ និង/ឬ ក្រៅបញ្ហាជាក់លាក់ដែលកំណត់ដោយ អ.ប.ជ ។អាស្រ័យហេតុនេះ គេមិនត្រូវការសារណាបែបនេះសម្រាប់ជាជំនួយក្នុងការវិនិច្ឆ័យទោសឲ្យបានត្រឹមត្រូវនោះទេ។ ហេតុដូច្នេះ មេធាវីការពារក្តីរួមស្នើសុំអង្គបុរេជំនុំជម្រះ បដិសេធទទួលយកសារណារទាំងនោះ។ សារណារបស់លោក Heindel បានគូសបញ្ជាក់ពីនិយមន័យនៃការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងតម្រូវការនានាសម្រាប់សម្រេចឲ្យបាននូវស្ថានភាពនៅ អ.វ.ត.ក[7]។ ស្របគ្នានេះដែរ មេធាវីការពារក្តីទទួលស្គាល់នូវសេចក្តី ត្រូវការការបកស្រាយចំពោះបញ្ហាដែលមិនទាន់បានដោះស្រាយនៅឡើយ[8]

---

[4] សូមមើលឯកសារលេខ C-11/36, “"សេចក្តីជូនដំណឹងជាសាធារណស្តីពីការដាក់សារណាអំពីការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងរឿងបណ្តឹងឧទ្ធរណ៍ជំទាស់នឹងការសម្រេចឃុំខ្លួនបណ្តោះអាសន្ន និងការអញ្ជើញអ្នកដែលមិនមែនភាគី (ហៅថា“សេចក្តីជូនដំណឹង”) កថាខណ្ឌ ៦ ។

[5] សូមមើលករណី *ព្រះរាជអាជ្ញា តទល់ជាមួយ Kallon* សំណុំរឿងលេខ SLSC [...] “សេចក្តីសម្រេចលើពាក្យសុំការអនុញ្ញាតដាក់សារណារបស់អ្នកដែលមិនមែនជាភាគីតុលាការ” ចុះនៅថ្ងៃទី ១ ខែវិច្ឆិកា ឆ្នាំ២០០៣ កថាខណ្ឌ ៥ ។

[6] សូមមើលករណីព្រះរាជអាជ្ញា តទល់ជាមួយ Semanza សំណុំរឿងលេខ ICTR [....]-T “សេចក្តីសម្រេចលើពាក្យសុំរបស់ព្រះរាជាណាចក្របែលហ្សិក ដើម្បីដាក់សារណា” ចុះនៅថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០០១ កថាខណ្ឌ ១០ ។

[7] សូមមើលឯកសារ C-11/38 ( “សារណារបស់ Heindel ”) កថាខណ្ឌ ១ដល់៥ ។

[8] ជាការពិតណាស់ មេធាវីការពារក្តីបានជំទាស់ថា អ.ប.ជ ពុំមានមានយុត្តាធិការដើម្បីអនុញ្ញាតឲ្យដើមបណ្តឹងរដ្ឋប្បវេណីចូលរួមក្នុងរឿងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះអាសន្ន ដោយសារតែ ក.ស.ច.ស មិនទាន់បានសម្រេចអំពីឋានៈរបស់ពួកគេនៅឡើយ ។ សូមមើលឯកសារលេខ C-11/45 (“សារណារួមគ្នា”) កថាខណ្ឌ១៩ ដល់ ២០ ។

ការចូលរួមបែបនេះក្រៅពីវិសាលភាពនៃបញ្ហាបច្ចុប្បន្ន ដែលកំណត់ត្រឹមតែបញ្ហាការចូលរួមរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណីក្នុងរឿងបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាឃុំខ្លួនបណ្តោះអាសន្ន តែប៉ុណ្ណោះ[9] ។

4. បន្ថែមពីលើនេះ សារណារបស់អ្នកដែលមិនមែនភាគី [Redress Trust] សហព័ន្ធសិទ្ធិមនុស្សអន្តរជាតិ (International Federation of Human Rights) និង មេធាវីគ្មានព្រំដែន (vocate sans Frontieres) ប៉ុនប៉ងបង្កើតទំនាក់ទំនងរវាងការបដិសេធការចូលរួមរបស់ភាគីរដ្ឋប្បវេណីក្នុងរឿងបណ្តឹងឧទ្ធរណ៍ប្រឆាំងការឃុំខ្លួនបណ្តោះអាសន្ន និងព្រាងដីកាចោទប្រកាន់[10] ។ សូមជម្រាបថាខ្លឹមសារសឹងតែទាំងអស់នៃសារណារបស់ Redress មិនបានគូសបញ្ជាក់ឲ្យបានច្បាស់លើបញ្ហានៅចំពោះមុខឡើយ ប៉ុន្តែ ជាជាងការរិះគន់ដែលមានលក្ខណៈទូទៅលើការចោទប្រកាន់ដែលមានន័យចង្អៀតនៅតុលាការព្រហ្មទណ្ឌអន្តរជាតិទៅវិញ ។ ជាការពិត ដើមបណ្តឹងរដ្ឋប្បវេណីមានសេរីភាពពេញលេញដើម្បីសម្របសម្រួលជាមួយ ក.ស.ព ក្នុងការបញ្ចេញទស្សនៈទាក់ទងទៅនឹងការចោទប្រកាន់ តាមយល់ឃើញរបស់ខ្លួនថាសមស្រប។ មេធាវីការពារក្តីស្នើថាបណ្តឹងឧទ្ធរណ៍ប្រឆាំងលើដីកាឃុំខ្លួនបណ្តោះអាសន្ន មិនមែនជាវេទិការមួយសមស្របសម្រាប់ការអនុវត្តសិទ្ធិបែបនេះឡើយ[11]

## ២. សារណាមួយចំនួនមានចន្លោះខ្វះខាត

5. វិធានផ្ទៃក្នុង និងសេចក្តីណែនាំអនុវត្តរបស់ អ.វ.ត.ក/០១/២០០៧ (ហៅថា "សេចក្តីណែនាំអនុវត្ត") កំណត់អំពីតម្រូវការបច្ចេកទេសទូទៅសម្រាប់ការដាក់ឯកសារនៅ អ.វ.ត.ក[12] ។ប៉ុន្តែ ករណីបច្ចុប្បន្ន អ.ប.ជ បានកំណត់យ៉ាងច្បាស់ថាសារណាទាំងអស់ត្រូវសរសេរជាភាសាអង់គ្លេសនិងបារាំងហើយត្រូវមានកំរាស់១០ទំព័រ[13] ។ ដោយពិចារណាពីចំណុចអវត្តមានអំពីរបៀបដាក់ឯកសារ មេធាវីការពារក្តីមិនបានចាត់ទុកបញ្ហានេះថាជាការប្រព្រឹត្តខុសតិចតួចនៅក្នុងសារណានិមួយៗនោះទេ[14]។

---

[9] សូមមើលកថាខណ្ឌ ៦ នៃដីកា: អាស្រ័យហេតុនេះ មេធាវីការពារក្តីមិនឆ្លើយតបចំពោះបញ្ហានេះ ប៉ុន្តែរក្សាសិទ្ធិឆ្លើយតបប្រសិនបើ អ.ប.ជ បង្ហាញបញ្ហានៅថ្ងៃក្រោយ ។ នៅក្នុងស្ថានករណ៍បែបនេះ មេធាវីការពារក្តីស្នើសុំឲ្យមានការពិគ្រោះយោបល់ និង ជូនដំណឹងឲ្យបានត្រឹមត្រូវទៅភាគីពាក់ព័ន្ធទាំងអស់ ប្រសិនបើតម្រូវ ។

[10] សូមមើលឯកសារលេខ C-11/42 ( "សារណារបស់ Redress") កថាខណ្ឌ ១៤ ។

[11] នៅក្នុងករណីណាមួយ ដោយពិចារណាលើវិសាលភាពនៃដីកាបញ្ជូនរឿងឲ្យស៊ើបសួររបស់ ក.ស.ពនិងការចោទប្រកាន់បឋមរបស់ ក.ស.ច.ស គេមិនអាចនិយាយបានថាវិសាលភាពនៃដំណើរការនីតិវិធីនៅ អ.វ.ត.ក មានលក្ខណៈតូចចង្អៀតបានឡើយ ។

[12] ឯកសារនេះអាចរកបានពីគេហទំព័ររបស់សាលាក្តី ។

[13] សូមមើលដីកា ទំព័រ២ ។

[14] ឧទាហរណ៍ សារណា Heindel (ហាក់ដូចជាប្រោះដោយដោយហ្វុនមានទំហំ១០ ) ។

00165879



ប៉ុន្តែ មេធាវីការពារក្តីប្រយ័ត្នប្រយែងចំពោះការដាក់ឯកសាររបស់ខ្លួនដែលមិនឲ្យលើសពីកំរាស់ ១០ ទំព័រដែលត្រូវបានកំណត់នោះទេ តែមេធាវីការពារក្តីជំទាស់ទៅនឹងសារណា Redress ដែលប្រើដោយហ្វុនអក្សរទំហំ៩ គ្មានគំលាតពីបន្ទាត់មួយទៅបន្ទាត់មួយទៀត (single-spaced) ហើយប្រើប្រភេទអក្សរ Arial/Helvetica ។អនុលោមទៅតាមលក្ខខណ្ឌនៃមាត្រា ៣.៨ នៃសេចក្តីណែនាំអនុវត្ត[15] តែឯកសារនេះដែលបង្កើតបានជាសារណាមានកំរាស់រហូតដល់១៥ ទំព័រឯណោះ ។ ដោយពិចារណាថាអ្នកនិពន្ធនៃសារណានេះ យល់ដឹងពីរបៀបរបបធ្វើការនៅតុលាការព្រហ្មទណ្ឌអន្តរជាតិផ្សេងៗ ហេតុដូច្នេះ មេធាវីការពារក្តីស្នើថាការប៉ុនប៉ងដើម្បីបញ្ចៀសការដាក់កំហិតទំព័រនេះ ត្រូវតែបដិសេធ ។

## ខ. ការចូលរួមរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណីក្នុងរឿងបណ្តឹងឧទ្ធរណ៍ប្រឆាំងលើដីកាឃុំខ្លួនបណ្តោះអាសន្ន ត្រូវហាមឃាត់ដោយច្បាប់ ឬ វិធានរបស់កម្ពុជា

6. មេធាវីការពារក្តីសូមបញ្ជាក់ពីគោលជំហររបស់ខ្លួនឡើងវិញថា ការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងរឿងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះអាសន្ន មិនត្រូវបានអនុញ្ញាតដោយច្បាប់ និង វិធានរបស់កម្ពុជាឡើយ[16] ។អំណះអំណាងនេះមិនត្រូវកាត់បន្ថយដោយសារណាភាគច្រើនដែលផ្តោតទៅលើតែបញ្ហាទូទៅទាក់ទងទៅនឹងការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី *raison d'être* ជាជាងការវិភាគដែលផ្តោតលើផលប្រយោជន៍របស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងដំណើរការឃុំខ្លួនបណ្តោះអាសន្ន ។

7. សារណាភាគច្រើនអះអាងថាវិធាន២៣(១)(ក)ចែងពីអាណត្តិយ៉ាងទូលំទូលាយសម្រាប់ចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីដោយគ្មានការរឹតត្បិត នៅគ្រប់ដំណាក់កាលទាំងអស់នៃដំណើរការនីតិវិធី[17] ។ ពិតមែនមេធាវីការពារក្តីមិនជំទាស់ពី "សារៈសំខាន់របស់ជនរងគ្រោះក្នុងការទទួលបានយុត្តិធម៌"[18] តែការទទួលបាននូវយុត្តិធម៌ត្រូវតែមានដែនកំណត់ដែរ ។ ជាជាងអត្ថិភាពនៃការគំរាមកំហែងមួយ

---

[15] មាត្រា ៣.៨ ចែងថា "អត្ថបទសរសេរជាភាសាបារាំង ឬ អង់គ្លេស ត្រូវព្រោះប្រភេទអក្សរ Time Roman មានទំហំ១២ ហើយគំលាតពីបន្ទាត់មួយទៅបន្ទាត់មួយទៀតត្រូវមានទំហំ ១.៥" ។

[16] សូមមើលសារណារួមគ្នា កថាខណ្ឌ ២១ ដល់ ២៣ ។

[17] សូមមើលឯកសារ C-11/44 ("សេចក្តីសន្និដ្ឋានឆ្លើយតបរបស់ ក.ស.ព") កថាខណ្ឌ ៧, សារណារបស់ Heindel ទំព័រ១ និង កថាខណ្ឌ ៦ និង ឯកសារលេខ C-11/40 ("សារណារបស់ KID") កថាខណ្ឌ ១, ៨, និង ១០ ។

[18] អត្ថបទរបស់ Carsten Stanh, Hector Olasolo និង Kate Gibson ស្តីពី "ការចូលរួមរបស់ជនរងគ្រោះនៅដំណាក់បុរេជំនុំជម្រះរបស់ ICC, ព្រឹត្តិបត្រយុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិ ៤ (Oxford 2006) p.230

លើការចូលរួមរបស់ដើមបណ្ដឹងរដ្ឋប្បវេណីនៅ អ.វ.ត.ក គោលជំហររបស់មេធាវីការពារក្ដីត្រូវតែបានមើលឃើញថាបានផ្ទុះបញ្ចាំងពីច្បាប់ដែលកំពុងនៅជាធរមាន ដែលមិនបានមាក់ងាយដល់ការចូលរួមរបស់ដើមបណ្ដឹងរដ្ឋប្បវេណីក្នុងរឿងបណ្ដឹងឧទ្ធរណ៍ប្រឆាំងដីកាឃុំខ្លួនបណ្ដោះអាសន្នឡើយ។ ការពាក់ព័ន្ធរបស់ភាគីដើមបណ្ដឹងរដ្ឋប្បវេណីនៅដំណាក់កាលអង្គបុរេជំនុំជម្រះ ត្រូវតែបានពិចារណាថាជាទស្សនាទានដំណើរការនីតិវិធីជាក់លាក់ ។ នៅពេលអានដំណាលគ្នា វិធាន ២៣(១) និង ៧៤(៤) មិនបានគាំទ្រដល់សេចក្ដីសន្និដ្ឋានណាផ្សេងឡើយ ។

8. វិធានផ្ទៃក្នុងមិនធូររលុង ដូចដែល ក.ស.ព ភាគីដើមបណ្ដឹងរដ្ឋប្បវេណី និងអ្នកដែលមិនមែនភាគីចង់បាននោះទេ ។ ការប៉ុនប៉ងទាញភាពខុសគ្នារវាងការអនុវត្តនៅតុលាការព្រហ្មទណ្ឌអន្តរជាតិ (ហៅថា "ICC") និងវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក សារណាភាគច្រើនបានកំណត់ឋានៈរបស់ភាគីដើមបណ្ដឹងរដ្ឋប្បវេណីថាជាភាគីពេញលេញ (full Parties) នៅក្នុងដំណើរការនីតិវិធីទាំងអស់របស់ អ.វ.ត.ក[19]។ ទោះបីជាមានភាពក្លែងក្លាយចំពោះសញ្ញាណរបស់ឋានៈនៃភាគីពេញលេញក៏ដោយ ក៏គោលជំហរនៃសារណាសំអាងលើវិធាន ៧៤ ដែលទទួលស្គាល់ការខ្វែងគំនិតក្នុងចំណោមភាគីទាក់ទងទៅនឹងសមត្ថភាពរបស់ពួកគេនៅចំពោះមុខ អ.ប.ជ ។ មានតែសហព្រះរាជអាជ្ញាទេអាចប្ដឹងឧទ្ធរណ៍នឹងដីការបស់សហចៅក្រមស៊ើបអង្កេតទាំងអស់ សូម្បីតែមេធាវីការពារក្ដីក៏មិនមានសិទ្ធិពេញលេញដែរ"ភាគីពេញលេញ" តាមស្មារតីនេះ ។ សរុបសេចក្ដីមក ដូចគ្នានឹងជនត្រូវចោទដែរ ឧបមាថានឹងមិនចូលរួមនៅក្នុងបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីការបស់ ក.ស.ច.ស មួយដែលបដិសេធសំណើសុំបដិទាននៃវត្ថុដែលរឹបអូសពីជនត្រូវចោទម្នាក់ទៀត ក៏ដូចភាគីដើមបណ្ដឹងរដ្ឋប្បវេណីដែរ មិនត្រូវមានសិទ្ធិចូលរួមក្នុងបណ្ដឹងឧទ្ធរណ៍ ប្រឆាំងដីកាឃុំខ្លួនបណ្ដោះអាសន្ន ។

9. ដោយពិចារណាពីសេចក្ដីត្រូវការឲ្យមានតុល្យភាពសិទ្ធិរបស់ជនត្រូវចោទ និងតថភាពនៃការអនុវត្តរបស់តុលាការប្រឆាំងនឹងសិទ្ធិរបស់ដើមបណ្ដឹងរដ្ឋប្បវេណី មធ្យោបាយដែលគាំទ្រដោយមេធាវីការពារក្ដី និងសាស្ត្រាចារ្យ Safferling គឺជាមធ្យោបាយមួយដែលមានលក្ខណៈប្រុងប្រយ័ត្នបំផុតសម្រាប់ដោះស្រាយកិច្ចបញ្ហាបច្ចុប្បន្ន ។ បណ្ដឹងឧទ្ធរណ៍ប្រឆាំងដីកាឃុំខ្លួនបណ្ដោះអាសន្ន ផលប្រយោជន៍របស់ដើមបណ្ដឹងរដ្ឋប្បវេណីដែលមានតែឈ្មោះ ចាំបាច់ត្រូវដាក់បញ្ចូលទៅក្នុងផលប្រយោជន៍ខាងយុត្តិធម៌ដែលមានន័យទូលំទូលាយ ឆ្លុះបញ្ចាំងពីលក្ខណៈវិនិច្ឆ័យសម្រាប់ការឃុំខ្លួនបណ្ដោះអាសន្ន ។ ផលប្រយោជន៍ទូទៅទាំងនេះត្រូវបានការពារយ៉ាងគ្រប់គ្រាន់ដោយ

[19] សារណារបស់ Heindel កថាខណ្ឌ ៧ ។

សហព្រះរាជអាជ្ញា ដោយមិនចាំបាច់នូវការជំនួយ និង ការឧបត្ថម្ភគាំទ្រឡើយ[20] ។ សំខាន់នេះទៅទៀត ដោយសារតែសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះអាសន្ន មិនមែនអង្គសេចក្តីទៅលើករណីដែលកំពង់តែស៊ើបអង្កេតនៅឡើយ ហេតុដូច្នេះមិនមានអនុភាពលើសមត្ថភាពរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីប្រមូលសំណងការខូតខាតឡើយ ។ មានការលំបាកដើម្បីយល់ច្បាស់នូវការពាក់ព័ន្ធរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណីអាចធ្វើយុត្តិកម្មយ៉ាងដូចម្តេច[21] ។

10. ជាចុងក្រោយ មានសំណូមពរថាការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បេណីនឹងផ្តល់"ឱកាសដល់ជនរងគ្រោះ ដើម្បីបង្ហាញការព្រួយបារម្ភ និងទស្សនៈទាំងអស់"[22]) មិនបានបំរើឲ្យគោលបំណងនៃបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះអាសន្នឡើយ ។ "សារៈសំខាន់ក្នុងចូលរួមដំណើររបស់ជនរងគ្រោះដែល ទទួលនូវការឈឺចាប់ គឺត្រូវបានទទួលស្គាលជាផ្លូវការ[23]" ដែលសមស្របនៅដំណាក់កាលនេះ ។ ការសន្មត់នីត្យានុកូលភាពនៃការព្រួយបារម្ភទូទៅទាំងនេះ នៅក្នុងបរិបទនៃសវនាការរឿងក្តីព្រហ្មទណ្ឌ បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះអាសន្ន គឺមិនមែនជាកាលៈទេសៈសមស្របដើម្បីផ្សព្វផ្សាយឡើយ ។ បណ្តឹងទាមទាររបស់ពួកគេត្រូវតែបានសម្រេចជាផ្លូវការដោយ ក.ស.ច.ស ។ ដើមបណ្តឹងរដ្ឋប្បវេណី នឹងមានឱកាសចូលរួមនៅក្នុងដំណើរការនីតិវិធីដែលគោលជំហររបស់ពួកគេត្រូវបានទទួលស្គាល់យ៉ាងច្បាស់ដោយវិធាន ។ ពុំមានផលប្រយោជន៏ជាប់ព័ន្ធជាមួយការចូលរួមរបស់ជនគ្រោះណាមួយ[24] នឹងត្រូវអន់ថយដោយសារ

---

[20] សូមកត់សំគាល់ថា ឧទាហរណ៏ សារណារបស់ Redress បានសន្និដ្ឋានអំពី"ការជាប់ទាក់ទងពិតប្រាកដនិងច្រើនគួរសម" រវាងជនរងគ្រោះ និង សុវត្ថិភាព និង សន្តិសុខរបស់ពួកគេ ។ ប៉ុន្តែ ពុំមានទឡ្ហីករណីដើម្បីគាំទ្រដល់ការសន្និដ្ឋាននេះឡើយ ។ តាមពិត សវនាការនាថ្ងៃទី៧-៨ ខែកុម្ភះ ឆ្នាំ២០០៨ មេធាវីរបស់ដើមបណ្តឹងរដ្ឋប្បវេណីនិយាយតែបញ្ហាទូទៅ ហើយមិនបានលើកឡើងនូវការគំរាមកំហែងមួយដល់សន្តិសុខផ្ទាល់ខ្លួនរបស់ដើមបណ្តឹងរដ្ឋប្បវេណីឡើយ ។

[21] សូមមើកសារណារបស់លោក Safferling ទំព័រ៣ ("មូលហេតុសម្រាប់ការរឹតត្បឹតទស្សនៈស្តីពីការចូលរួមរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណីអាចត្រូវមើលឃើញ ដោយសារតែការឃុំខ្លួនបណ្តោះអាសន្នមិនមានអនុភាពលើគោលជំហររបស់ជនរងគ្រោះ វាបំរើផលប្រយោជន៏យុត្តិធម៏ និង ប្រសិទ្ធិភាពខាងយុត្តិធម៏ ហើយមិនបំរើសេចក្តីត្រូវការរេកជនទេ [...] ។ បញ្ហាថាតើត្រូវតែឃុំខ្លួនជនជាប់ចោទចោទ ឬមិនឃុំខ្លួននោះ វាមិនបានប៉ះពាល់គោលជំហរផ្លូវច្បាប់របស់ជនរងគ្រោះ ជាភាគីដើមបណ្តឹងរដ្ឋប្បវេណីក្នុងដំណើរវិនិច្ឆ័យទោសឡើយ") ។

[22] សារណារបស់ Redress កថាខណ្ឌ ១២ ។

[23] សារណារបស់ Redress កថាខណ្ឌ ១២ ។

[24] សូមមើលសារណារបស់ ក.ស.ព កថាខណ្ឌ ២០, សារណារបស់ Redress កថាខណ្ឌ ១២ ។

ការផាត់ចោលភាគីដើមបណ្ដឹងរដ្ឋប្បវេណីពីដំណើរការនីតិវិធីក្នុងបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួនបណ្ដោះអាសន្នឡើយ ។

**គ. ការចូលរួមរបស់ភាគីរដ្ឋប្បវេណីនៅក្នុងបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួនបណ្ដោះអាសន្ន ធ្វើឱ្យប៉ះពាល់ជាអវិជ្ជមានដល់សិទ្ធិជាមូលដ្ឋានរបស់ជនត្រូវចោទ**

11. មេធាវីការពារក្ដីបានលើកឡើងពីហានិភ័យថា ការចូលរួមរបស់ភាគីរដ្ឋប្បវេណីអាចធ្វើឱ្យប៉ះពាល់ដល់សិទ្ធិរបស់ជនត្រូវចោទក្នុងការទទួលបានការកាត់សេចក្ដីមួយដែលពុំមានការអូសបន្លាយពេលវេលា សច្ចធារណ៍នៃនិរទោស និងគោលការណ៍ស្ដីពីសមភាពនៃគូភាគី។[25] នៅក្នុងសារណាដ៏ធំនេះ គ្មានអ្វីដែលបានកាត់បន្ថយការព្រួយបារម្ភនោះឡើយ តែផ្ទុយទៅវិញ ជំហររបស់ ក.ស.ព និង*អ្នកដែលមិនមែនជាភាគីតុលាការ* កាន់តែធ្វើឱ្យលេចឡើងនូវហានិភ័យ ដែលមេធាវីការពារក្ដីបានលើកឡើងនោះ។

12. សិទ្ធិទទួលបាននូវការពិចារណាភ្លាមៗលើការឃុំខ្លួនបណ្ដោះអាសន្ន គឺជាសិទ្ធិមូលដ្ឋាន។[26] យោងតាមបទពិសោធន៍របស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិ (ICC) សារណារបស់ Heindel បានគាំថា ការតម្រូវឱ្យភាគីរដ្ឋប្បវេណីដាក់ពាក្យបណ្ដឹងសុំចូលរួម អាចនាំឱ្យមានការពន្យារដល់ដំណើរការនីតិវិធីយ៉ាងខ្លាំង និងហេតុនេះហើយ គឺវាមិនចាំបាច់នោះទេ។[27] មេធាវីការពារក្ដីសូមស្នើឱ្យ អង្គបុរេជំនុំជម្រះធ្វើសេចក្ដីសន្និដ្ឋានផ្ទុយ: ដោយការវែកញែកថា លក្ខខណ្ឌនៃការដាក់ពាក្យបណ្ដឹងគឺពុំមានជម្រើសនោះទេ ដូចដែលអង្គជំនុំជម្រះសាលាឧទ្ធរណ៍របស់ ICC បានទទួលស្គាល់ថា នីតិវិធីបែបនេះគឺមានសារៈសំខាន់ដល់ការធានាដល់ការការពារសិទ្ធិរបស់ជនត្រូវចោទ។[28]

---

[25] *សូមមើល*សារណារួមគ្នា កឋាខ័ណ្ឌ ២៧ ដល់ ៣០ ។

[26] នៅតុលាការអន្តរជាតិផ្សេងទៀត សិទ្ធិនេះត្រូវបានអនុវត្តជាក់ស្ដែង ដោយការកម្រិតនូវកាលបរិច្ឆេទផុតកំណត់ការដាក់ពាក្យប្ដឹងដែលត្រូវធ្វើឱ្យបានរួសរាន់ចំពោះបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួនបណ្ដោះអាសន្ន។ ឧទាហរណ៍ បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងការដោះលែងបណ្ដោះអាសន្ននៅ ICC"ត្រូវដាក់ពាក្យបណ្ដឹងដោយដើមបណ្ដឹងឧទ្ធរណ៍នៅក្នុងរយៈពេលប្រាំពីរថ្ងៃ គិតពីថ្ងៃជូនដំណឹងពីសេចក្ដីសម្រេចដែលពាក់ព័ន្ធ។ សារណាឆ្លើយតបត្រូវដាក់ជូននៅក្នុងរយៈពេលប្រាំថ្ងៃ គិតពីថ្ងៃជូនដំណឹងពីឯកសារដែលគាំទ្រដល់បណ្ដឹងឧទ្ធរណ៍នេះ"។ បទបញ្ជារបស់តុលាការ ICC ឯកសារលេខ ICC-BD/០១-០១-០៤ បទបញ្ជាលេខ ៦៤(៥)។ ចំនុចនេះធានាថា ដោយការមិនអនុញ្ញាតឱ្យមានការចូលរួមពីភាគី រដ្ឋប្បវេណី នោះការប្ដឹងឧទ្ធរណ៍ត្រូវធ្វើនៅចំពោះមុខអង្គជំនុំជម្រះសាលាឧទ្ធរណ៍ ឱ្យបានឆាប់រហ័សតាមដែលអាចធ្វើ ទៅបាន។

[27] *សូមមើល*កឋាខ័ណ្ឌ ៦ ដល់ ៨ ។

[28] *សូមមើល*ឧទាហរណ៍ សូមមើល រដ្ឋអាជ្ញា តទល់នឹង Thomas Lubanga Dyilo សំណុំរឿងលេខ ICC-០១/០៤-០១/០៦ "សាលដីកាស្ដីពីការប្ដឹងឧទ្ធរណ៍របស់លោក Thomas Lubanga Dyilo ប្រឆាំងនឹងសេចក្ដីសម្រេចរបស់ អង្គបុរេជំនុំជម្រះ I" ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០០៧ កឋាខ័ណ្ឌ [...] ដូចគ្នា។ "សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះ

ដោយការខ្វះខាតការចង្អុលបង្ហាញពីផលប្រយោជន៍នៅក្នុងការប្ដឹងឧទ្ធរណ៍ប្រឆាំងទៅនឹងការឃុំខ្លួនបណ្ដោះអាសន្ន តាមការពិតទៅបច្ច័យដែលសមស្របបំផុតនោះ គឺអវត្តមាននៃការចូលរួមរបស់ភាគីរដ្ឋប្បវេណី។ ជនត្រូវចោទមិនត្រូវបានគេបង្ខំឲ្យជ្រើសរើសរវាងសិទ្ធិទទួលបានការកាត់សេចក្ដីប្រកបដោយយុត្តិធម៌ និងសិទ្ធិទទួលបានការកាត់សេចក្ដីដោយគ្មានការអូសបន្លាយពេលវេលានោះឡើយ[29]។

13. សច្ចធារណ៍នៃនិរទោស ដែលមានចែងក្នុងវិធាន ២១(១)(ឃ) ក៏អាចត្រូវបានរំលោភដោយការអនុញ្ញាតឲ្យភាគីរដ្ឋប្បវេណីចូលរួមក្នុងសវនាការស្ដីពីការឃុំខ្លួនបណ្ដោះអាសន្នផងដែរ។ ចំនុចនេះត្រូវបានធ្វើឡើង(ដោយអចេតនា) ដោយការដាក់សារណា Redress ដែលបានលើកឡើង: "ដោយហេតុថា អន្តរាគមន៍ជាក់លាក់មួយមិនបានចង្អុលបង្ហាញ ឬឆ្លើយតបឲ្យបានច្បាស់លាស់ទៅនឹងពិរុទ្ធភាពជាក់លាក់ណាមួយរបស់ជនត្រូវចោទ ពាក់ព័ន្ធទៅនឹងបទចោទទាំងឡាយ នោះវាពិបាកដឹងថាតើភាពលំអៀងប៉ុនណាដែលអាចកើតមានឡើងនោះ"។[30] ជាក់ស្ដែង អ្នកធ្វើសារណា Redress មិនមានវត្តមាននៅក្នុងសវនាការលើបណ្ដឹងឧទ្ធរណ៍កាលពីថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០០៨ នោះទេ នៅពេលដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ សេង ចាន់ធារី បានលើកឡើងថា: "ប្រសិនបើ នួន ជា អះអាងថាគាត់មិនទទួលខុសត្រូវទេ អញ្ចឹងអ្នកណាជាអ្នកធ្វើឲ្យបាត់បង់ឪពុកម្ដាយរបស់ខ្ញុំ និងអ្នកដែលជាទីស្រឡាញ់របស់ជនរងគ្រោះដទៃទៀត?"[31]។ ទោះបីជាពុំមានការមន្ទិលសង្ស័យចំពោះភាពស្មោះត្រង់ក៏ដោយ ក៏សារណាទាំងនោះមានចេតនាយ៉ាងច្បាស់ក្រឡែតក្នុងការទាក់ទាញ អ.ប.ជ ឲ្យជឿថា ជនត្រូវចោទមានពិរុទ្ធភាព ដែលជាបញ្ហាមួយមិនមានការទាក់ទងគ្នាបន្តិចសោះទៅនឹងដំណោះស្រាយលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ននោះ។

14. ជាចុងក្រោយ សមភាពនៃគូភាគីដែលត្រូវតែមានតុល្យភាពយ៉ាងពិតប្រាកដ ដែលតម្រូវឲ្យតុលាការនេះប្រកាន់យកឲ្យបានខ្ជាប់ខ្ជួននោះ អាចនឹងមិនមានភាពយុត្តិធម៌លំអៀងទៅ ក.ស.ព ប្រសិនបើភាគីរដ្ឋប្បវេណីត្រូវបានអនុញ្ញាតឲ្យចូលរួមនៅក្នុងបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួនបណ្ដោះអាសន្ននោះ។ ផ្ទុយពីការរក្សាឲ្យបាននូវសមភាពនៅក្នុងបន្ទប់សវនាការ ពាក់ព័ន្ធទៅនឹងពេលវេលា

---

សាលាឧទ្ធរណ៍ទៅលើសារណារួមគ្នារបស់ជនរងគ្រោះ a/០០០១/០៦ ដល់ a/០០០៣/០៦ និង a/០១០៥/០៦ ចុះថ្ងៃទី ១៣ ខែកុម្ភៈ ឆ្នាំ២០០៧ កថាខ័ណ្ឌ [...]។

29 មេធាវីការពារកត់សំគាល់ឃើញថា បញ្ហានៃការចូលរួមរបស់ភាគីរដ្ឋប្បវេណីបានបណ្ដាលឲ្យមានការយឺតយ៉ាវយ៉ាងខ្លាំងនៅក្នុងការសម្រេចសេចក្ដីលើការផ្អាកសវនាការរបស់លោក នួន ជា។

30 សារណា Redress កថាខ័ណ្ឌ ២៨ ។

31 *សូមមើល* ឯករាជ្យភាព "រយៈពេល ៣០ ឆ្នាំក្រោយមក ជនរងគ្រោះនៃរបបខ្មែរក្រហមបានប្រឈមមុខនឹងមេដឹកនាំនៅក្នុងតុលាការ" ចុះថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០០៨ ។

ដែលអាចមានសម្រាប់ការធ្វើសារណាផ្ទាល់មាត់នោះ ក.ស.ព តាមរយៈ "ពាក្យសំដីអនាមិក"របស់ភាគីរដ្ឋប្បវេណី ពិតជាអាចទទួលបានពេលវេលាច្រើនជាងពីរដងនៃពេលវេលាដែលបានផ្តល់ជូនមេធាវីការពារ។ ចំនុចត្រង់នេះ អាចនឹងផ្តល់គុណវិបត្តិយ៉ាងធ្ងន់ធ្ងរដល់ជនត្រូវចោទ នៅពេលធ្វើការបង្ហាញរឿងក្តីរបស់ខ្លួន[32] និងអាចតម្រូវឱ្យមានការផ្តល់ធនធានបន្ថែមទៀត ក្នុងខណៈដែលបញ្ហាថវិការបស់ អ.វ.ត.ក កំពុងតែមានសម្ពាធកាន់តែខ្លាំងឡើងនោះ[33]។

15. ក.ស.ព និងភាគីមិត្តមិនមែនតុលាការបានពិភាក្សាគ្នាលើសេចក្តីសម្រេចមួយចំនួនរបស់តុលាការសិទ្ធិមនុស្សសហភាពអឺរ៉ុប ("ECHR")។ ជាពិសេស សារណារបស់ ក.ស.ព បានតវ៉ាថា ECHR "បានទទួលស្គាល់សិទ្ធិរបស់ជនរងគ្រោះ និងសាច់ញាតិរបស់ពួកគេយ៉ាងច្រើន ដែលពាក់ព័ន្ធនៅក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌ រួមទាំងនៅគ្រប់ដំណាក់កាលស៊ើបអង្កេតផង"[34] បន្ថែមលើនេះ សារណា Redress បាននិយាយយោងទៅដល់ការទទួលស្គាល់ពីសារៈសំខាន់នៃការពិនិត្យពិច័យជា សាធារណៈយ៉ាងល្អិតល្អន់របស់ ECHR ទៅលើការស៊ើបអង្កេត។[35] សារណារបស់អង្គការ ADHOC បាននិយាយយោងទៅលើយុត្តាធិការរបស់ ECHR ប៉ុន្តែ មិនបានធ្វើការចង្អុលបង្ហាញ ជាក់លាក់ណាមួយដើម្បីគាំទ្រការអះអាងរបស់ខ្លួននោះឡើយ។[36] ទោះជាយ៉ាងណាក៏ដោយ ដោយសារតែបញ្ហានេះមាននៅក្នុងដៃទៅហើយ នោះថាតើភាគីរដ្ឋប្បវេណីត្រូវបានអនុញ្ញាតឱ្យចូលរួមក្នុងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះអាសន្នដែរឬទេនោះ ជាជាង*ដំណើរការនីតិវិធីស៊ើបអង្កេត* នោះយុត្តិសាស្ត្រដែលបានលើកឡើងមិនមានការជាប់ទាក់ទិននោះទេ ហើយក៏មិនបានគាំទ្រដល់ជំហរភាគច្រើននោះដែរ។

16. បើទោះបីជា ECHR មិនបានប្រកាសបដិសេធទាំងស្រុងនូវការចូលរួមរបស់ភាគីរដ្ឋប្បវេណីនៅក្នុងសវនាការប្រឆាំងនឹងការឃុំខ្លួនបណ្តោះអាសន្នក៏ដោយ ក៏មាត្រា ៦(១) នៃ ECHR ដែលបាន

---

[32] *សូមមើល រដ្ឋអាជ្ញា តទល់នឹង Milutinović និងជនដទៃទៀត* សំណុំរឿងលេខ IT-០៥-៨៧-A "សេចក្តីសម្រេចទៅលើបណ្តឹងឧទ្ធរណ៍បន្ទាន់បង្គំស្តីពីពាក្យស្នើសុំថវិកាបន្ថែម" ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០០៣ កឋាខ័ណ្ឌ ២៤ ។

[33] ចំណាំ: ទាក់ទិននឹងបញ្ហានេះ សូមមើល "របាយការណ៍ស្តីពីប្រតិបត្តិការទៅលើប្រព័ន្ធជំនួយផ្នែកច្បាប់សម្រាប់ជនក្រីក្រ របស់ [អ.វ.ត.ក] និងសំណើសុំធ្វើវិសោធនកម្មរបស់តុលាការនេះ" ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០៧ ASP ៦-៤ កឋាខ័ណ្ឌ ៣៥ (iii) ដែលបានអនុញ្ញាតឱ្យមានបុគ្គលិកបំរើការងារពេញម៉ោងបន្ថែមម្នាក់ទៀត ដែលមានកំរិតកាំប្រាក់ អ.ស.ប P2 ក្នុងកម្រៃ ៦.១១៣ € (អឺរ៉ូ) ក្នុងមួយខែ សម្រាប់ជនរងគ្រោះចំនួន ៥០ (នាក់) ដែលត្រូវបានអនុញ្ញាតឱ្យចូលរួមនៅក្នុងដំណើរការនីតិវិធីនៅ អ.វ.ត.ក ។

[34] សារណារបស់ អ.ស.ព កឋាខ័ណ្ឌ ១៧ ។

[35] សារណារបស់ Redress កឋាខ័ណ្ឌ ២១ ។

[36] សារណារបស់អង្គការ ADHOC កឋាខ័ណ្ឌ ៣.១ ដល់ ៣.២ ។

ចែងយ៉ាងច្បាស់នោះមិនបាន "អនុញ្ញាតចំពោះសិទ្ធិមាន"កំហឹងផ្ទាល់ខ្លួន" ឬសកម្មភាពសាធារណៈនោះទេ"[37]។ អាស្រ័យហេតុនេះ ទាំងការសំដែងចេញនូវគំនិតចងគំនុំ ឬ ទស្សនៈជាសាធារណៈសុទ្ធសាធ មិនមានការជាប់ទាក់ទិននៅក្នុងសវនាការប្រឆាំងនឹងការឃុំខ្លួនបណ្តោះអាសន្ននោះឡើយ។ លើសពីនេះទៅទៀត ប្រសិនបើយុត្តិសាស្ត្ររបស់ ECHR ពិតជាបានលើកឡើងពីការចូលរួមរបស់ភាគីរដ្ឋប្បវេណីនៅក្នុងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះអាសន្នមែននោះ នោះវាអាចចោទឡើងនូវសំណួរជាច្រើន ថាតើមានអ្នកណាម្នាក់អាចអនុវត្តយុត្តាធិការរបស់តុលាការនេះប្រកបដោយប្រសិទ្ធភាពបាន បើប្រៀបធៀបទៅនឹងតុលាការឧក្រិដ្ឋកម្មអន្តរជាតិ ក្នុងករណីដែលជនរងគ្រោះរាប់ពាន់នាក់ទំនងជាស្នើសុំចូលរួមនៅក្នុងដំណើរការនីតិវិធីនោះ។ ដូចគ្នានេះដែរ ប្រភពអន្តរជាតិផ្សេងទៀតដែលបានលើកជាសំអាងនៅក្នុងសារណារបស់ Redress មិនអាចត្រូវបានបកស្រាយដើម្បីអនុវត្តចំពោះបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួនបណ្តោះអាសន្នបានទេ[38]។

## ង. របបដែលបានស្នើសុំសម្រាប់ការចូលរួមរបស់ភាគីរដ្ឋប្បវេណីសំខាន់ៗ

17. ប្រសិនបើ អ.ប.ជ សម្រេចថាវាសមស្របសម្រាប់ការអនុញ្ញាតឲ្យភាគីរដ្ឋប្បវេណីចូលរួមនៅក្នុងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួនបណ្តោះអាសន្ន នោះមេធាវីការពារក្តីសូមស្នើឲ្យមានការដាក់កម្រិតរបបដូចខាងក្រោមនេះ: ផ្ទុយពីចំនុចដែលបានស្នើសុំដោយក.ស.ព ដើម្បីការពារដល់សិទ្ធិរបស់ជនត្រូវចោទ និងធានាដល់ការប្រព្រឹត្តទៅនៃសវនាការឧទ្ធរណ៍ឲ្យបានឆាប់រហ័ស និង សមស្រប:

ក. មានតែបុគ្គលដែលពាក្យបណ្តឹងរបស់ខ្លួនត្រូវបានពិនិត្យឡើងវិញយ៉ាងល្អិតល្អន់ និងបានយល់ព្រមដោយសហចៅក្រមស៊ើបអង្កេតទេ ទើបត្រូវបានទទួលស្គាល់ថាជាភាគីរដ្ឋប្បវេណី។ ការទទួល

---

[37] Perez តទល់នឹង ប្រទេសបារាំង ECHR ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០០៤ កថាខ័ណ្ឌ ៧០ ។

[38] *សូមមើល*សារណារបស់ Redress កថាខ័ណ្ឌ ២០។ គ្មានច្បាប់ក្នុងប្រទេសណាមួយត្រូវបានយកមកផ្លាស់ប្តូរភាពដូចគ្នា (mutatis mutandis) ចំពោះដំណើរការនីតិវិធីរបស់ អ.វ.ត.ក បានឡើយ។ ការពិតនោះគឺថា នីតិវិធីព្រហ្មទណ្ឌរបស់កម្ពុជាកើតចេញពីទំនាក់ទំនងអាណានិគមរបស់ខ្លួនជាមួយប្រទេសបារាំង នោះវាមិនបានធ្វើយុត្តិកម្មចំពោះសំណូមពររបស់អង្គការ ADHOC ស្នើសុំឲ្យដកចេញនូវការបកស្រាយរបស់ ICC ដើម្បីគាំទ្រដល់នីតិវិធីច្បាប់បារាំង។ *សូមមើល* សារណារបស់អង្គការ ADHOC កថាខ័ណ្ឌ ១.១៣ និង ១.២៤។ ទោះជាយ៉ាងណាក៏ដោយ មេធាវីការពារសូមអញ្ជើញ អ.ប.ជ ពិចារណាលើ កំណត់បង្ហាញរបស់ Robert Badinter ដែលជាអ្នកជំនាញផ្នែកឧក្រិដ្ឋវិទ្យារបស់បារាំងម្នាក់: "យុត្តិធម៌ព្រហ្មទណ្ឌមិនមានបេសកកម្មព្យាបាលការឈឺចាប់របស់ជនរងគ្រោះនោះទេ។ វាមានមុខងារបង្រ្កាប ធ្វើឲ្យ រួញរា និងសំដែងឲ្យឃើញច្បាស់ ព្រោះវាបានគាត់តែងនូវតម្លៃសង្គម។ ប៉ុន្តែ វាពុំមានគោលបំណងព្យាបាលនោះទេ"។

ស្គាល់ផ្លូវការបែបនេះ ត្រូវតែជាលក្ខខណ្ឌតម្រូវជាមុនដាច់ខាតសម្រាប់ការចូលរួមរបស់ភាគីរដ្ឋប្បវេណីនៅក្នុងបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួនបណ្ដោះអាសន្ន។

ខ. នៅពេលត្រូវបានទទួលស្គាល់បែបនោះហើយ ភាគីរដ្ឋប្បវេណីណាមួយមានបំណងចូលរួមនៅក្នុងបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួនបណ្ដោះអាសន្ន ត្រូវដាក់ពាក្យស្នើសុំមក អ.ប.ជ ក្នុងទម្រង់ជាសារណាឆ្លើយទៅនឹងសារណាដ៏សំខាន់របស់ដើមបណ្ដឹង និងក្នុងករណីណាក៏ ដោយបន្ទាប់ពីការដាក់សារណាដោយ ក.ស.ព ពាក្យស្នើសុំនេះត្រូវកំណត់ឲ្យច្បាស់ថាតើ:

i. ផលប្រយោជន៍ផ្ទាល់ខ្លួនរបស់ភាគីរដ្ឋប្បវេណី ត្រូវបានប៉ះពាល់ដោយបណ្ដឹងឧទ្ធរណ៍នេះដោយរបៀបណា។

ii. ហេតុអ្វីបានជាវាសមស្របសម្រាប់ឲ្យ អ.ប.ជ អនុញ្ញាតឲ្យមានបង្ហាញពីទស្សនៈ យល់ឃើញ និងការព្រួយបារម្ភពីភាគីរដ្ឋប្បវេណី ជាពិសេស:

- ថាតើសារណារបស់ ក.ស.ព ខកខានមិនបានលើកឡើងពីការព្រួយបារម្ភផ្ទាល់ខ្លួនរបស់ភាគីរដ្ឋប្បវេណីដោយរបៀបណា
- ថាតើហេតុអ្វីបានជា ក.ស.ព មិនមានចេតនា ឬមិនអាចដាក់ជូនសារណាក្នុងនាមឲ្យភាគីរដ្ឋប្បវេណី និង
- ថាតើ និងហេតុអ្វីបានជាភាគីរដ្ឋប្បវេណីត្រូវបានអនុញ្ញាតឲ្យធ្វើសារណាផ្ទាល់មាត់នៅក្នុងសវនាការ និង

iii. ហេតុអ្វីបានជាការបង្ហាញពីទស្សនៈយល់ឃើញ និងការព្រួយបារម្ភបែបនោះមិនធ្វើឲ្យប៉ះពាល់ដល់ ឬមិនស្របជាមួយសិទ្ធិរបស់ជនត្រូវចោទ។

ក្នុងការរៀបចំដាក់ពាក្យសុំបែបនេះ ភាគីរដ្ឋប្បវេណីត្រូវពិនិត្យឡើងវិញពីសារណារបស់ ក.ស.ព និងទំនាក់ទំនងជាមួយ ក.ស.ព ទៅលើទស្សនៈយល់ឃើញទាំងនោះដើម្បីដាក់បញ្ចូលនូវជំហររួមគ្នា នៅពេលដែលមានភាគីរដ្ឋប្បវេណីច្រើនស្នើសុំចូលរួមនៅក្នុងបណ្ដឹងឧទ្ធរណ៍ដូចគ្នា នោះតម្រូវឲ្យមានពាក្យស្នើសុំរួមគ្នាមួយ ក្រៅពីទំនាស់ផលប្រយោជន៍ដែលត្រូវបង្ហាញរវាង ឬក្នុងចំណោមភាគីរដ្ឋប្បវេណីផ្សេងៗ។

គ. ត្រូវផ្ដល់ពេលវេលាឲ្យបានគ្រប់គ្រាន់ដល់ដើមបណ្ដឹងឧទ្ធរណ៍ ដើម្បីឆ្លើយតបទៅនឹងពាក្យសុំចូលរួមរបស់ភាគីរដ្ឋប្បវេណី ឲ្យស្របតាមមាត្រា ៨.៤ នៃសេចក្ដីណែនាំអនុវត្ត ហើយ អ.ប.ជ ត្រូវធ្វើដីកាជូនដំណឹងពីកាលបរិច្ឆេទ ដោយបញ្ជាក់លំអិត ក្នុងចំណោមបញ្ហាផ្សេងៗ ពីបញ្ហាដែលបាន

យល់ព្រមដល់ភាគីរដ្ឋប្បវេណី និងវិសាលភាពនៃការចូលរួមរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសវនាការ។

18. ខុសពីសារណាភាគច្រើន វិធីបែបនេះនឹងមិនធ្វើឱ្យប៉ះពាល់ខ្លាំងដល់ការជឿនលឿននៃដំណើរការនីតិវិធីលើបណ្តឹងឧទ្ធរណ៍នោះឡើយ។ ដោយការធានាជាមុនថា ការចូលរួមពីសំណាក់ភាគីដើមបណ្តឹងរដ្ឋប្បវេណីគឺអាស្រ័យទៅលើផលប្រយោជន៍ផ្ទាល់ខ្លួន ដែលអាចយកមកបង្ហាញឱ្យឃើញថាមានការពាក់ព័ន្ធ និងសមស្របទៅនឹងកាលៈទេសៈ និងមិនធ្វើឱ្យប៉ះពាល់ដល់សិទ្ធិរបស់ជនត្រូវចោទ ដែលខុសពីការអនុញ្ញាតឱ្យចូលរួមដោយគ្មានកម្រិត ដែលនឹងជួយសន្សំពេលវេលាតុលាការ និង ជួយលើកស្ទួយដល់សវនាការឧទ្ធរណ៍ដែលងាយយល់បានច្បាស់ និងមានការយកចិត្តទុកដាក់។

## III. សេចក្តីសន្និដ្ឋាន

19. សម្រាប់ហេតុផលដែលបានលើកឡើងខាងលើ និងដែលមាននៅក្នុងសារណារួមគ្នានេះ មេធាវីការពារក្តីស្នើសុំឱ្យ អ.ប.ជ ដកចេញសារណារបស់ដើមបណ្តឹងរដ្ឋប្បវេណីពីសំណុំរឿងបណ្តឹងឧទ្ធរណ៍របស់ នួន ជា និងច្រានចោលការចូលរួមក្រោយៗទៀតរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅ ក្នុងដំណើរការនីតិវិធីលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួនបណ្តោះអាសន្ន នាពេលអនាគត។ ជាជម្រើសមេធាវីការពារស្នើសុំឱ្យមានការអនុវត្តរបបដែលបានស្នើឡើងស្តីពីការចូលរួមរបស់ ភាគីរដ្ឋប្បវេណី។

មេធាវីរបស់ នួន ជា:

សុន អរុណ　　　　　Michiel PESTMAN និង Victor KOPPE

AVOCAT ATTORNEY AT LAW KINGDOM OF CAMBODIA

មេធាវីបរទេស សារី:

អាង ឧត្តម　　　　　Michael KANAVAS

មេធាវីរបស់ អៀង ធីរិទ្ធ:

ព្រះរាជាណាចក្រកម្ពុជា មេធាវី AVOCAT ATTORNEY AT LAW KINGDOM OF CAMBODIA

ផាត់ ពៅស៊ាង                    Diana ELLIS QC (ទីប្រឹក្សាច្បាប់)